## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តត្បូងឃ្មុំ**

លេខ: ០៥៤ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពគណៈកម្មាធិការជម្រុញចលនាភូមិ១ ផលិតផល១ ខេត្តត្បូងឃ្មុំ

## អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៤/៦២៩ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤ ត្រាស់បង្គាប់តែងតាំងអភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៣/១០៥៩ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិ ជំរុញចលនាភូមិមួយផលិតផលមួយ ដោយធ្វើសមាហរណកម្មការងារជំរុញចលនាភូមិមួយផលិតផលមួយ ឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ
- យោងសេចក្តីសម្រេចលេខ ០៥ សសរ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ របស់សាលាខេត្តត្បូងឃ្មុំ ស្តីពីការបែងចែក និងប្រគល់ភារកិច្ចជូនឯកឧត្តមអភិបាល និងអភិបាលរងនៃគណៈអភិបាលខេត្តត្បូងឃ្មុំ
- យោងលិខិតលេខ០២៩ក.១ផ.១ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទស្តីពីការណែនាំឲ្យរដ្ឋបាលខេត្តរៀបចំគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១
- យោងសេចក្តីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ របស់សាលាខេត្តត្បូងឃ្មុំ ស្តីពីការបង្កើតគណៈកម្មាធិការខេត្តត្បូងឃ្មុំជម្រុញចលនាភូមិ១ ផលិតផល១

## សម្រេច

**ប្រការ ១**. ត្រូវបានកែសម្រួលសមាសភាពគណៈកម្មាធិការជម្រុញចលនាភូមិ១ ផលិតផល១ ខេត្តត្បូងឃ្មុំ សរសេរកាត់ថា ( គ.ខ.ភ១ ផ១) ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ប្រាជ្ញ ចន្ទ** | អភិបាលខេត្ត | ប្រធាន |
| ២- ឯកឧត្តម | **ម៉ែន កុសល្យ** | អភិបាលរងខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- លោក | **ហោច ពិសិដ្ឋ** | ប្រធានមន្ទីរកសិកម្មខេត្ត | សមាជិក |
| ៤- លោក | **តួច សុខន** | ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត | សមាជិក |
| ៥- លោក | **អ៊ិន ពៅសម្បត្តិ** | ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត | សមាជិក |
| ៦- លោក | **កខ ចន្ទីរិទ្ធ** | ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្ត | សមាជិក |
| ៧- លោក | **ស ស៊ីណា** | ប្រធានមន្ទីរព័ត៌មានខេត្ត | សមាជិក |

| | | | |
|---|---|---|---|
| ៨- លោក | **កែវ វណ្ណៈ** | ប្រធានមន្ទីរសុខាភិបាលខេត្ត | សមាជិក |
| ៩- លោក | **អេង ណារ៉េត** | ប្រធានមន្ទីរផែនការខេត្ត | សមាជិក |
| ១០- លោក | **ហួរ ពិសិដ្ឋ** | ប្រធានមន្ទីរបរិស្ថានខេត្ត | សមាជិក |
| ១១- លោក | **អាន ស៊ីណា** | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | សមាជិក |
| ១២- លោកស្រី | **ថន គីមស្រ៊ន់** | អនុប្រធានមន្ទីរកិច្ចការនារីខេត្ត | សមាជិកា |
| ១៣- លោក | **ម៉ិញ ឈាងហ៊ន់** | ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត | សមាជិក |
| ១៤- លោក | **អឿន រិទ្ធ** | ប្រធានមន្ទីរទេសចរណ៍ខេត្ត | សមាជិក |
| ១៥- លោក | **អ៊ុន លំអេង** | ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាខេត្ត | សមាជិក |
| ១៦- លោក | **អ៊ុំ វាសនា** | ប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | សមាជិក |
| ១៧- លោក | **អៀម ម៉ាយ៉ុងរី** | នាយខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ | សមាជិក |
| ១៨- លោក | **ឡុង ឆាម** | អភិបាលស្រុកពញាក្រែក | សមាជិក |
| ១៩- លោក | **នាដ្ឋ វ៉ាឌុឆ** | អភិបាលស្រុកតំបែរ | សមាជិក |
| ២០- លោក | **ចេង ម៉ុណ្ណារ៉ា** | អភិបាលស្រុកមេមត់ | សមាជិក |
| ២១- លោក | **ស្រេង លី** | អភិបាលស្រុកក្រូចឆ្មារ | សមាជិក |
| ២២- លោក | **កេង ម៉ុនណា** | អភិបាលស្រុកត្បូងឃ្មុំ | សមាជិក |
| ២៣- លោក | **ជា ណារ៉ុន** | អភិបាលក្រុងសួង | សមាជិក |
| ២៤- លោក | **ខួន ម៉ុណ្ណាន** | អភិបាលស្រុកអូររាំងឪ | សមាជិក |
| ២៥- លោក | **ម៉ៅ ឌុង** | នាយករងរដ្ឋបាល សាលាខេត្ត | សមាជិក |

**ប្រការ២.** គណៈកម្មាធិការ ជម្រុញចលនាភូមិ១ ផលិតផល១ ខេត្តត្បូងឃ្មុំ មានភារកិច្ចដូចខាងក្រោម ៖

- សម្របសម្រួលយ៉ាងជិតស្និត ជាមួយនឹងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១
- ជម្រុញការអនុវត្តចលនាភូមិ១ ផលិតផល១ ឲ្យទទួលបានជោគជ័យដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្រ្តចតុកោណជំហានទី៣ និង ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល
- អភិវឌ្ឍធនធានមនុស្សទាក់ទងនឹងការជម្រុញចលនាភូមិ១ផលិតផល១នៅថ្នាក់ខេត្ត ដើម្បីអនុវត្តចលនាភូមិ១ផលិតផល១ឲ្យទទួលបានជោគជ័យរួមចំណែកកាត់បន្ថយភាពក្រីក្រ កាត់បន្ថយចំណាកស្រុក លើកកម្ពស់ជីវភាពរស់នៅ និងគុណភាពជីវិតរបស់ប្រជាជនតាមសហគមន៍
- ចូលរួម និងដឹកនាំការសិក្សាស្រាវជ្រាវផលិតផលជាសក្តានុពលនានា ដែលមាននៅក្នុងខេត្តទាំងផលិតផលជាវត្ថុធាតុដើម ផលិតផលកែច្នៃ និងផលិតផលសេវាកម្មដើម្បីបញ្ចូលទៅក្នុងចលនាភូមិ១ផលិតផល១ ដោយធ្វើយ៉ាងណាបន្តអភិវឌ្ឍផលិតផលទាំងនោះមានលក្ខណៈកាន់តែប្រសើរកាន់តែពិសេស និងសមស្របតាមទីផ្សារទាំងក្នុងសហគមន៍ ក្នុងប្រទេស និងក្រៅប្រទេស
- ផ្សព្វផ្សាយឲ្យបានទូលំទូលាយពីសារៈសំខាន់នៃការជម្រុញចលនាភូមិ១ ផលិតផល១ និងលើកទឹកចិត្តប្រជាជននៅតាមមូលដ្ឋានឲ្យចូលរួមគាំទ្រ និងអនុវត្តចលនានេះ

- សម្របសម្រួលជាមួយអង្គការ ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានានៅថ្នាក់ក្រោមជាតិ ដើម្បីជម្រុញការអនុវត្តចលនាភូមិ១ ផលិតផល១
- សម្របសម្រួលរៀបចំអនុវត្តយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីផែនការសកម្មភាពជំរុញចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត
- រៀបចំបង្កើតសមាគម ឬសហគមន៍គាំទ្រចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត
- រៀបចំបង្កើតមជ្ឈមណ្ឌលភូមិ១ ផលិតផល១ នៅក្នុងខេត្ត សម្រាប់ធ្វើជាកន្លែងសិក្សាស្រាវជ្រាវ បណ្តុះបណ្តាល ផ្សព្វផ្សាយ ប្រមូលផ្តុំ និងដាក់តាំងបង្ហាញ ឬ លក់ផលិតផលភូមិ១ ផលិតផល១
- រៀបចំបង្កើតអនុគណៈកម្មាធិការក្រុង ស្រុក ជម្រុញចលនាភូមិ១ ផលិតផល១ ដោយសមាសភាពនិងតួនាទីរបស់អនុកម្មាធិការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការខេត្ត ជម្រុញញចលនាភូមិ១ ផលិតផល១
- រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ជម្រុញញចលនាភូមិ១ ផលិតផល១ និងថ្នាក់ដឹកនាំខេត្ត និងចម្លងជូនមន្ទីរ ស្ថាប័នពាក់ព័ន្ធក្នុងខេត្ត ដើម្បីរួមសហប្រតិបត្តិការក្នុងការជម្រុញចលនាភូមិ១ ផលិតផល១។

**ប្រការ៣.** ត្រូវបានបង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការជម្រុញចលនាភូមិ១ ផលិតផល១ ខេត្តត្បូងឃ្មុំ ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- លោក | **ម៉ៅ ឌុច** | នាយករងរដ្ឋបាល សាលាខេត្ត | ប្រធាន |
| ២- លោក | **ស៊ុន សារ៉ាត់** | អនុប្រធានមន្ទីរកសិកម្មខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| **៣-លោក លោកស្រី អភិបាលរង ក្រុង ស្រុក ទទួលបន្ទុក** | | | អនុប្រធាន |
| ៤- លោក | **ខ៉ា ចាន់ឡឿន** | នាយករងទីចាត់ការអន្តរវិស័យសាលាខេត្ត | សមាជិក |
| ៥.លោក | **សយ ឆូច** | នាយករងទីចាត់ការផែនការ និងវិនិយោគ សាលាខេត្ត | សមាជិក |
| ៦-លោក | **ចាន់ ទណ្ណៈ** | ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត (ទទួលបន្ទុកតាមដានទទួលខុសត្រូវបូកសរុបរបាយការណ៍) | សមាជិក |
| ៧-លោក | **អេាក មុខ្សៀ** | អនុប្រធានការិយាល័យសេដ្ឋកិច្ចនិងសង្គមកិច្ច សាលាខេត្ត (ទទួលបន្ទុកតាមដានទទួលខុសត្រូវបូកសរុបរបាយការណ៍) | សមាជិក |
| ៨-លោក | **គង់ ស៊ីថត្ថា** | អនុប្រធានការិយាល័យស្ថិតិនិងអគ្រានុកូលដ្ឋាន សាលាខេត្ត (ទទួលបន្ទុកតាមដានទទួលខុសត្រូវបូកសរុបរបាយការណ៍) | សមាជិក |

**ប្រការ៤.** លេខាធិការដ្ឋាននៃគណៈកម្មាធិការជម្រុញចលនាភូមិ១ ផលិតផល១ ខេត្តត្បូងឃ្មុំ មានភារកិច្ចដូចខាងក្រោម ៖

- ជាសេនាធិការឱ្យគណៈកម្មាធិការជម្រុញចលនាភូមិ១ផលិតផល១ខេត្ត ក្នុងការចាត់ចែងការងាររដ្ឋបាលបូកសរុបរបាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ រៀបចំការ

ប្រជុំកសាងផែនការ សកម្មភាពត្រួតពិនិត្យតាមដាន វាយតម្លៃលើការអនុវត្តន៍ការងារជម្រុញចលនាភូមិ១ ផលិតផល១

- ធ្វើការសម្របសម្រួលជាមួយបណ្តាមន្ទីរ អង្គភាពជុំវិញខេត្ត សាលាក្រុង-ស្រុក អង្គការមិនមែនរដ្ឋាភិបាល ដើម្បីក្តាប់ជាប់នូវប្រព័ន្ធព័ត៌មាន របាយការណ៍ពាក់ព័ន្ធការងារត្រួតពិនិត្យការជម្រុញចលនាភូមិ១ ផលិតផល១
- រៀបចំផែនការបណ្តុះបណ្តាល សិក្ខាសាលា ផ្សព្វផ្សាយ ដល់មន្ត្រីពាក់ព័ន្ធនៅតាមអង្គភាពសហគមន៍ មហាជននៅតាមមូលដ្ឋាន និងនិស្សិត សិស្សានុសិស្សតាមគ្រឹះស្ថានសិក្សានានា ពាក់ព័ន្ធនឹងការជម្រុញចលនាភូមិ១ ផលិតផល១
- រៀបចំធ្វើរបាយការណ៍នានាក្នុងនាមគណៈកម្មាធិការជម្រុញចលនាភូមិ១ ផលិតផល១ ខេត្តត្បូងឃ្មុំ ឱ្យបានទាន់ពេលវេលាតាមការកំណត់របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជម្រុញចលនាភូមិ១ ផលិតផល១ និងថ្នាក់ដឹកនាំខេត្ត និងចម្លងជូនមន្ទីរស្ថាប័នពាក់ព័ន្ធក្នុងខេត្ត ដើម្បីរួមសហប្រតិបត្តិការក្នុងការជម្រុញចលនា ភូមិ១ផលិតផល១
- អនុប្រធានអចិន្ត្រៃយ៍លេខាធិការដ្ឋានជម្រុញចលនាភូមិ១ ផលិតផល១ ត្រូវរ៉ាប់រងការងារជំនួសប្រធានលេខាធិការដ្ឋានក្នុងការដោះស្រាយការងារប្រចាំថ្ងៃ និងធានានិរន្តភាពនៃដំណើរការងារក្នុងលេខាធិការដ្ឋានឱ្យមានសកម្មភាពរស់រវើកនិងមានភាពរលូន ហើយត្រូវរាយការណ៍ជូនប្រធានលេខាធិការដ្ឋានអំពីការចាត់ចែងការងារទាំងនោះ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីគណៈកម្មាធិការជម្រុញចលនាភូមិ១ ផលិតផល១ ខេត្តត្បូងឃ្មុំ ។

**ប្រការ៥**. សេចក្តីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ របស់សាលាខេត្ត ត្រូវបានចាត់ទុកជានិរាករណ៍ ។

**ប្រការ៦**. នាយករដ្ឋបាលសាលាខេត្ត អភិបាលស្រុក ក្រុង ប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធនានាជុំវិញខេត្ត ព្រមទាំង ឯកឧត្តម អស់លោក លោកស្រី ដូចមានឈ្មោះក្នុងប្រការ១ និងប្រការ៣ ខាងលើ ត្រូវអនុវត្តតាមសេចក្តីសម្រេច នេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ត្បូងឃ្មុំ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៦

**អភិបាលខេត្ត និងជាប្រធាន**

**គណៈកម្មាធិការជម្រុញចលនាភូមិ១ ផលិតផល១ ខេត្ត**

**ប្រាជ្ញ ចន្ទ**

**កន្លែងទទួល៖**

-ក្រសួងមហាផ្ទៃ

-អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជម្រុញចលនាភូមិ១ ផលិតផល១

-ក្រុមប្រឹក្សាខេត្ត

"ដើម្បីគោរពជូនជ្រាប"

-ដូចប្រការ៦ "ដើម្បីអនុវត្ត"

-ឯកសារ កាលប្បវត្តិ